**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១៧៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការអនុវត្តច្បាប់ស្តីពីកាតព្វកិច្ចយោធា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥២៦/០០៨ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកាតព្វកិច្ចយោធា
- បានឃើញអនុក្រឹត្យលេខ០៨ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៧ ស្តីពីរបបឧបត្ថម្ភចំពោះយោធិនពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ
- បានឃើញអនុក្រឹត្យលេខ២១៨ អនក្រ.បក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា៧ជំពូកទី៣នៃអនុក្រឹត្យលេខ០៨ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៧ ស្តីពីរបបឧបត្ថម្ភចំពោះយោធិនពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ
- យោងតាមសំណូមពរចាំបាច់នៃការងារ

# សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីលក្ខខណ្ឌនិងបែបបទនៃការធ្វើជំរឿន ការជ្រើសរើស ការអញ្ជើញ ការពន្យារពេល ប្រាក់ឧបត្ថម្ភ គោលរបបផ្សេងៗ និងការលើកទឹកចិត្ត ព្រមទាំងបែបបទនិងនីតិវិធីក្នុងការទទួលយកប្រជាពលរដ្ឋដែលបញ្ចប់កាតព្វកិច្ចយោធាឱ្យចូលបម្រើការងារឬបន្តការសិក្សាវិញ ដើម្បីធានាការអនុវត្តច្បាប់ស្តីពីកាតព្វកិច្ចយោធាប្រកបដោយតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព។

**មាត្រា២ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះប្រជាពលរដ្ឋខ្មែរដែលមានអាយុដូចខាងក្រោម៖

- អាយុចាប់ពី ១៧ (ដប់ប្រាំពីរ) ឆ្នាំ ដល់ ២៥ (ម្ភៃប្រាំ) ឆ្នាំ សម្រាប់ការធ្វើជំរឿន
- អាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំ ដល់ ២៥ (ម្ភៃប្រាំ) ឆ្នាំ ដែលត្រូវបំពេញកាតព្វកិច្ចយោធារយៈពេល ២៤ (ម្ភៃបួន) ខែ។

**មាត្រា៣ .-**

វាក្យសព្ទដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចតទៅ៖

- យោធិន សំដៅដល់ប្រជាពលរដ្ឋខ្មែរដែលកំពុងបំពេញកាតព្វកិច្ចយោធា ដែលមានរយៈពេលដូចមានចែងក្នុងច្បាប់ស្តីពីកាតព្វកិច្ចយោធា
- យោធិនពលី សំដៅដល់យោធិនកំពុងបំពេញកាតព្វកិច្ចយោធា ដែលបានបាត់បង់ជីវិតក្នុងពេលប្រយុទ្ធ បម្រើការប្រយុទ្ធ ក្នុងបេសកកម្មហ្វឹកហាត់ជំនាញគ្រោះថ្នាក់បំផុត ធ្វើការពិសោធដ៏មានគ្រោះថ្នាក់ និងដោយសារគ្រោះថ្នាក់ធម្មជាតិ
- យោធិនមរណៈ សំដៅដល់យោធិនកំពុងបំពេញកាតព្វកិច្ចយោធា ដែលបានទទួលបញ្ជាទៅបំពេញការងារក្នុងតំបន់ធម្មតាហើយត្រូវទទួលគ្រោះថ្នាក់បាត់បង់ជីវិតដោយសារការងារទាំងនោះឬដោយសារជំងឺ
- យោធិនពិការ សំដៅដល់យោធិនកំពុងបំពេញកាតព្វកិច្ចយោធា ដែលបានបាត់បង់សរីរាង្គណាមួយ ឬច្រើននៅលើរាងកាយដោយសារបានចូលរួមប្រយុទ្ធ បម្រើការប្រយុទ្ធ ហ្វឹកហាត់ជំនាញមានគ្រោះថ្នាក់ ធ្វើការពិសោធដ៏មានគ្រោះថ្នាក់ និងដោយសារគ្រោះថ្នាក់ធម្មជាតិឬទទួលបញ្ជាទៅបំពេញបេសកកម្មក្នុងតំបន់ធម្មតាហើយត្រូវទទួលគ្រោះថ្នាក់
- ជនទេសន្តរប្រវេសន៍ការងារ សំដៅដល់ប្រជាពលរដ្ឋខ្មែរដែលកំពុងធ្វើការងារ ឬចុះកម្មសិក្សា ឬហាត់ការនៅក្រៅប្រទេស។

## ជំពូកទី២
## លក្ខខណ្ឌនៃការធ្វើជំរឿន ការជ្រើសរើស ការអញ្ជើញ និងការអនុវត្តកាតព្វកិច្ចយោធា
### ផ្នែកទី១
### ការធ្វើជំរឿន

**មាត្រា៤ .-**

ការធ្វើជំរឿន ត្រូវអនុវត្តចំពោះប្រជាពលរដ្ឋខ្មែរភេទប្រុសដែលមានអាយុចាប់ពី ១៧ (ដប់ប្រាំពីរ) ឆ្នាំ ដល់ ២៥ (ម្ភៃប្រាំ) ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ដើម្បីទទួលបានទិន្នន័យពិតប្រាកដក្នុងការសម្រេចអញ្ជើញចូលបំពេញកាតព្វកិច្ចយោធា។

បញ្ជីជំរឿនត្រូវធ្វើឡើងតាមរយៈការប្រមូលទិន្នន័យពីក្រសួងមហាផ្ទៃ ឬប្រមូលទិន្នន័យនិងរបាយការណ៍ពីរដ្ឋបាលឃុំ សង្កាត់ ឬធ្វើឡើងតាមរយៈការចុះធ្វើជំរឿនដោយផ្ទាល់។

**មាត្រា៥ .-**

ការធ្វើបញ្ជីជំរឿនកាតព្វកិច្ចយោធា ត្រូវប្រព្រឹត្តទៅពីដើមខែតុលារហូតដល់ដំណាច់ខែធ្នូជារៀងរាល់ឆ្នាំ។

## ផ្នែកទី២

## ការជ្រើសរើស

**មាត្រា៦ .-**

ការជ្រើសរើសប្រជាពលរដ្ឋដើម្បីចូលបំពេញកាតព្វកិច្ចយោធា ត្រូវអនុវត្តដូចខាងក្រោម៖

- ការចូលបំពេញកាតព្វកិច្ចយោធាដោយស្ម័គ្រចិត្ត
- ការចូលបំពេញកាតព្វកិច្ចយោធាតាមការចាប់ឆ្នោត។

**មាត្រា៧ .-**

លក្ខណសម្បត្តិប្រជាពលរដ្ឋដែលត្រូវជ្រើសរើសឱ្យចូលបំពេញកាតព្វកិច្ចយោធា ត្រូវមានលក្ខខណ្ឌដូចការជ្រើសរើសយោធិនអាជីពដែរ។

## ផ្នែកទី៣

## ការអញ្ជើញ

**មាត្រា៨ .-**

ប្រជាពលរដ្ឋដែលត្រូវបានជ្រើសរើស ត្រូវទទួលបានការអញ្ជើញដល់សាមីខ្លួនដោយផ្ទាល់ឱ្យចូលបំពេញកាតព្វកិច្ចយោធា តាមចំនួនតម្រូវការប្រចាំឆ្នាំ។

ប្រជាពលរដ្ឋដែលត្រូវបានអញ្ជើញឱ្យចូលបំពេញកាតព្វកិច្ចយោធា ត្រូវបង្ហាញខ្លួនក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃដែលសាមីខ្លួនបានទទួលដំណឹង។

**មាត្រា៩ .-**

ប្រជាពលរដ្ឋដែលត្រូវបានអញ្ជើញឱ្យចូលបំពេញកាតព្វកិច្ចយោធា ត្រូវមកបង្ហាញខ្លួនតាមពេលវេលា និងទីកន្លែងដែលកំណត់ក្នុងលិខិតអញ្ជើញ។

ប្រជាពលរដ្ឋដែលត្រូវមកបង្ហាញខ្លួន ត្រូវយកមកជាមួយនូវឯកសារមួយចំនួនដូចជា៖

- លិខិតអញ្ជើញប្រជាពលរដ្ឋឱ្យចូលបំពេញកាតព្វកិច្ចយោធា
- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរនិង/ឬបណ្ណសម្គាល់ខ្លួនសិស្ស និស្សិត។

## ផ្នែកទី៤

## ការអនុវត្តកាតព្វកិច្ចយោធា

**មាត្រា១០ .-**

ការគ្រប់គ្រង ការចាត់តាំង ការហ្វឹកហ្វឺនយោធិនបំពេញកាតព្វកិច្ចយោធាដែលបានជ្រើសរើសរួច និងការអនុញ្ញាតឱ្យវិលត្រឡប់ទៅកាន់ជីវភាពស៊ីវិលវិញនៃប្រជាពលរដ្ឋដែលបានបញ្ចប់កាតព្វកិច្ចយោធា ជាសមត្ថកិច្ចរបស់ក្រសួងការពារជាតិនិងអគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ។

ការធានាជីវភាពយោធិនបំពេញកាតព្វកិច្ចយោធា ជាសមត្ថកិច្ចរបស់ក្រសួងការពារជាតិនិងអគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ។

ក្រសួងការពារជាតិនិងអគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ ត្រូវរៀបចំកម្មវិធីហ្វឹកហ្វឺន ដោយអាចរួមបញ្ចូលទាំងការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។

## ជំពូកទី៣
## លក្ខខណ្ឌនិងបែបបទនៃការពន្យារពេល

**មាត្រា១១ .-**

ប្រជាពលរដ្ឋជាសិស្ស និស្សិតដែលកំពុងសិក្សា ឬជនទេសន្តរប្រវេសន៍ការងារ ឬមន្ត្រីរាជការដែលកំពុងបំពេញបេសកកម្មនៅក្រៅប្រទេស អាចទទួលបានការអនុញ្ញាតឱ្យពន្យារពេល ១ (មួយ) ឆ្នាំម្តងៗ ចំនួន ៤ (បួន) ដង។

រយៈពេលនៃការពន្យារពេល ត្រូវបូកបន្ថែមទៅលើអាយុដែលត្រូវបំពេញកាតព្វកិច្ចយោធា។

**មាត្រា១២ .-**

ប្រជាពលរដ្ឋជាសិស្ស និស្សិតដែលកំពុងសិក្សា ឬជនទេសន្តរប្រវេសន៍ការងារ ឬមន្ត្រីរាជការដែលកំពុងបំពេញបេសកកម្មនៅក្រៅប្រទេស ត្រូវដាក់ពាក្យសុំពន្យារពេលរបស់ខ្លួនដោយបញ្ជាក់មូលហេតុនិងមានការបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច។

ការសម្រេចអនុញ្ញាតឱ្យពន្យារពេលចូលបំពេញកាតព្វកិច្ចយោធា ត្រូវមានសេចក្តីសម្រេចជាផ្លូវការពីគណៈកម្មាធិការជាតិកាតព្វកិច្ចយោធាដូចមានចែងក្នុងមាត្រា២០នៃអនុក្រឹត្យនេះ។

ការឆ្លើយតបចំពោះការស្នើសុំពន្យារពេលរបស់ប្រជាពលរដ្ឋជាសិស្ស និស្សិតដែលកំពុងសិក្សា ឬជនទេសន្តរប្រវេសន៍ការងារ ឬមន្ត្រីរាជការដែលកំពុងបំពេញបេសកកម្មនៅក្រៅប្រទេស ត្រូវធ្វើឡើងក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការយ៉ាងយូរ ក្រោយពេលទទួលពាក្យសុំរបស់សាមីខ្លួន។

រាល់ការពន្យារពេល ត្រូវពិនិត្យឡើងវិញជារៀងរាល់ឆ្នាំ ដោយគណៈកម្មាធិការជាតិកាតព្វកិច្ចយោធា ដូចមានចែងក្នុងមាត្រា២០នៃអនុក្រឹត្យនេះ។

## ជំពូកទី៤
## ការបញ្ចប់កាតព្វកិច្ចយោធា

**មាត្រា១៣ .-**

ក្រសួងការពារជាតិ ត្រូវចេញលិខិតបញ្ជាក់ពីការបញ្ចប់កាតព្វកិច្ចយោធាដល់ប្រជាពលរដ្ឋដែលបានបំពេញកាតព្វកិច្ចយោធា។

**មាត្រា១៤ .-**

ប្រជាពលរដ្ឋដែលបានបញ្ចប់កាតព្វកិច្ចយោធា ត្រូវបញ្ចូលទៅបម្រើការងារវិញក្នុងក្របខ័ណ្ឌដើមរបស់ស្ថាប័នរដ្ឋ សហគ្រាសសាធារណៈឬឯកជននានា និងអង្គការសង្គមស៊ីវិល ដោយរក្សាមុខតំណែងដូចមុនពេលទៅបំពេញកាតព្វកិច្ចយោធា។

សហគ្រាសសាធារណៈឬឯកជននានា និងអង្គការសង្គមស៊ីវិល ដែលមិនព្រមទទួលយកប្រជាពលរដ្ឋដែលបានបញ្ចប់កាតព្វកិច្ចយោធាឱ្យចូលបម្រើការងារវិញនិងរក្សាមុខតំណែងដូចមុនពេលទៅបំពេញកាតព្វកិច្ចយោធា ត្រូវផ្តល់ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារនិងសោហ៊ុយជំងឺចិត្តស្របតាមច្បាប់ស្តីពីការងារ។

**មាត្រា១៥ .-**

គ្រឹះស្ថានសិក្សាឬគ្រឹះស្ថានអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ ត្រូវទទួលឱ្យសិស្ស និស្សិត ដែលបានបញ្ចប់កាតព្វកិច្ចយោធាបន្តការសិក្សាវិញ ដោយរក្សាលទ្ធផលនៃការសិក្សាកន្លងមករបស់សាមីជន។

## ជំពូកទី៥

## ប្រាក់ឧបត្ថម្ភ គោលរបបផ្សេងៗ និងការលើកទឹកចិត្ត

### ផ្នែកទី១

### ប្រាក់ឧបត្ថម្ភនិងគោលរបបផ្សេងៗចំពោះយោធិនកំពុងបំពេញកាតព្វកិច្ចយោធា

**មាត្រា១៦ .-**

យោធិនកំពុងបំពេញកាតព្វកិច្ចយោធា ត្រូវទទួលបានប្រាក់ឧបត្ថម្ភប្រចាំខែនិងគោលរបបផ្សេងៗ ដូចខាងក្រោម៖

ក-ប្រាក់ឧបត្ថម្ភប្រចាំខែក្នុងម្នាក់ចំនួន ៤០០ ០០០ (បួនសែន) រៀល។

ខ-គោលរបបផ្សេងៗត្រូវទទួលបានដូចយោធិនអាជីពរួមមាន៖

- ប្រាក់ម្ហូបប្រចាំថ្ងៃ
- ប្រាក់អាហារបំប៉នបន្ថែមពេលហ្វឹកហាត់
- ប្រាក់បំណាច់ឧបត្ថម្ភគ្រួសារនិងកូន
- របបអង្ករប្រចាំថ្ងៃ
- របបឯកសណ្ឋានប្រយុទ្ធនិងបរិក្ខារចាំបាច់មួយចំនួន។

**មាត្រា១៧ .-**

យោធិនមានជំងឺ ឬរងរបួស ឬគ្រោះថ្នាក់ផ្សេងៗ ត្រូវទទួលបានការសង្គ្រោះ ការព្យាបាល និង ការថែទាំពីក្រសួងការពារជាតិ។

### ផ្នែកទី២

### គោលរបបផ្សេងៗចំពោះយោធិនពលី មរណៈ ឬពិការ

**មាត្រា១៨ .-**

យោធិនពលី មរណៈ ឬពិការ ដោយសារបុព្វហេតុជាតិមាតុភូមិពេលបំពេញបេសកកម្មក្នុងអំឡុងពេល នៃការបំពេញកាតព្វកិច្ចយោធា ត្រូវទទួលបានគោលរបបដូចតទៅ៖

ក-យោធិនកំពុងបំពេញកាតព្វកិច្ចយោធាហើយដែលពលី ត្រូវទទួលបានគោលរបបដូចយោធិន អាជីពពលីឋានន្តរសក្ដិពលទោ។

ខ-យោធិនកំពុងបំពេញកាតព្វកិច្ចយោធាហើយដែលទទួលមរណភាព ត្រូវទទួលបានគោលរបប ដូចយោធិនអាជីពមរណៈឋានន្តរសក្ដិពលទោ។

គ-យោធិនកំពុងបំពេញកាតព្វកិច្ចយោធាដែលមានជំងឺ របួស ក្លាយជាយោធិនពិការដោយចូលរួម ប្រយុទ្ធ បម្រើការប្រយុទ្ធ ហ្វឹកហាត់ជំនាញគ្រោះថ្នាក់ ធ្វើការពិសោធដ៏មានគ្រោះថ្នាក់ និងដោយសារ គ្រោះថ្នាក់ធម្មជាតិ ត្រូវទទួលបានគោលរបបដូចយោធិនអាជីពពិការប្រភេទ "ក" ឋានន្តរសក្ដិពលទោ។ ចំពោះយោធិនដែលមានជំងឺ របួស ក្លាយជាយោធិនពិការដោយទទួលបញ្ជាទៅបំពេញបេសកកម្មក្នុងតំបន់ ធម្មតា ហើយទទួលគ្រោះថ្នាក់ ត្រូវទទួលបានគោលរបបដូចយោធិនអាជីពពិការប្រភេទ "ខ"។

## ផ្នែកទី៣
## ការលើកទឹកចិត្ត

**មាត្រា១៩ .-**

យោធិនដែលបានបញ្ចប់កាតព្វកិច្ចយោធា ត្រូវទទួលបានការលើកទឹកចិត្តដូចខាងក្រោម៖

- មានអាទិភាពទទួលបានការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈនៅក្នុងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈសាធារណៈ
- មានអាទិភាពក្នុងការជ្រើសរើសចូលបម្រើជាយោធិនអាជីពក្នុងកងយោធពលខេមរភូមិន្ទ។

## ជំពូកទី៦
## បទប្បញ្ញត្តិដោយឡែក
## ផ្នែកទី១
## ការបង្កើតគណៈកម្មាធិការជាតិកាតព្វកិច្ចយោធា

**មាត្រា២០ .-**

ត្រូវបានបង្កើតគណៈកម្មាធិការជាតិកាតព្វកិច្ចយោធា ដែលសរសេរជាអក្សរកាត់ថា **គ.ក.យ.** មានសមាសភាពដូចតទៅ៖

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងការពារជាតិ | ប្រធាន |
| - រដ្ឋលេខាធិការក្រសួងការពារជាតិ ១រូប | អនុប្រធានអចិន្ត្រៃយ៍ |
| - អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ | អនុប្រធាន |
| - មេបញ្ជាការកងទ័ពជើងគោក | អនុប្រធាន |
| - មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងយុត្តិធម៌ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសុខាភិបាល ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ ១រូប | សមាជិក |
| - តំណាងខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី ១រូប | សមាជិក |
| - មេបញ្ជាការកងទ័ពជើងអាកាស | សមាជិក |
| - មេបញ្ជាការកងទ័ពជើងទឹក | សមាជិក |
| - អគ្គលេខាធិការ អគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ | សមាជិក |
| - អគ្គនាយក អគ្គនាយកដ្ឋានយោធសេវា ក្រសួងការពារជាតិ | សមាជិក |
| - អគ្គនាយក អគ្គនាយកដ្ឋានភស្តុភារ ហិរញ្ញវត្ថុ ក្រសួងការពារជាតិ | សមាជិក |
| - នាយរងសេនាធិការចម្រុះអគ្គបញ្ជាការដ្ឋាន ១រូប | សមាជិក |
| - មេបញ្ជាការរងកងទ័ពជើងគោក ១រូប | សមាជិក |
| - មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស ១រូប | សមាជិក |
| - នាយក នាយកដ្ឋានបុគ្គលិក ក្រសួងការពារជាតិ | សមាជិក |

- នាយក នាយកដ្ឋាននីតិកម្ម ក្រសួងការពារជាតិ សមាជិក
- នាយក នាយកដ្ឋានសុខាភិបាល ក្រសួងការពារជាតិ សមាជិក
- ក្រុមអ្នកច្បាប់ប្រចាំក្រសួងការពារជាតិ ១រូប សមាជិក
- នាយក ទីចាត់ការបុគ្គលិកអគ្គបញ្ជាការដ្ឋាន សមាជិក
- នាយក ទីចាត់ការឃោសនាព័ត៌មានអគ្គបញ្ជាការដ្ឋាន សមាជិក
- នាយកខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ សមាជិក។

សមាសភាពជាក់ស្តែងនៃ **គ.ក.យ.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**គ.ក.យ.** អាចមានសមាសភាពបន្ថែមតាមការចាំបាច់ ដែលត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

អនុប្រធាននិងសមាជិកនៃ **គ.ក.យ.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន **គ.ក.យ.**។ ក្នុងករណីចាំបាច់ ប្រធាន **គ.ក.យ.** អាចប្រគល់សិទ្ធិជូនអនុប្រធានណាម្នាក់ ដើម្បីអញ្ជើញនិងដឹកនាំកិច្ចប្រជុំជំនួសបាន។

ប្រធាន **គ.ក.យ.** មានសិទ្ធិអញ្ជើញប្រធានស្ថាប័ន ឬតំណាងរបស់ប្រធានស្ថាប័ន ឬអាជ្ញាធរ ឬឥស្សរជន ព្រមទាំងមន្ត្រីបច្ចេកទេសនៃក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ចូលរួមប្រជុំតាមការចាំបាច់។

**មាត្រា២១ .-**

**គ.ក.យ.** មានតួនាទីនិងភារកិច្ចដូចតទៅ៖

- ដឹកនាំការជ្រើសរើសប្រជាពលរដ្ឋដែលត្រូវបំពេញកាតព្វកិច្ចយោធាប្រចាំឆ្នាំ តាមចំនួនកំណត់ដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាល
- កំណត់អំពីបែបបទនិងនីតិវិធីនៃការធ្វើជំរឿនកាតព្វកិច្ចយោធា
- កំណត់នីតិវិធីចាប់ឆ្នោតជ្រើសរើសប្រជាពលរដ្ឋចូលបំពេញកាតព្វកិច្ចយោធា
- ដឹកនាំការផ្សព្វផ្សាយតាមគ្រប់មធ្យោបាយអំពីច្បាប់ស្តីពីកាតព្វកិច្ចយោធាដល់ប្រជាពលរដ្ឋខ្មែរគ្រប់រូប
- ពិនិត្យនិងសម្រេចទម្រង់បែបបទគំរូ ខ្លឹមសារសេចក្តីសម្រេច សេចក្តីណែនាំ និងវិធាននានាក្នុងដំណើរការអនុវត្តច្បាប់ស្តីពីកាតព្វកិច្ចយោធា
- ពិនិត្យនិងសម្រេចសមាសភាពប្រជាពលរដ្ឋដែលត្រូវអញ្ជើញឱ្យចូលបំពេញកាតព្វកិច្ចយោធា សុំពន្យារពេល និងរួចផុតពីកាតព្វកិច្ចយោធា
- ពិនិត្យនិងដោះស្រាយបណ្តឹងតវ៉ារបស់ប្រជាពលរដ្ឋដែលត្រូវអញ្ជើញឱ្យចូលបំពេញកាតព្វកិច្ចយោធា
- ដឹកនាំនិងផ្តល់យោបល់តម្រង់ទិសដល់ការអនុវត្តការងាររបស់គណៈកម្មាធិការកាតព្វកិច្ចយោធាគ្រប់ថ្នាក់តាមឋានានុក្រម
- ពិនិត្យនិងសម្រេចលើផែនការថវិការួមរបស់គណៈកម្មាធិការដែលមានចែងក្នុងជំពូកទី៦នៃអនុក្រឹត្យនេះ រួចបញ្ជូនទៅក្រសួងការពារជាតិ ដើម្បីដាក់ជាកញ្ចប់ថវិកាដោយឡែកនៃគម្រោងថវិការបស់ក្រសួងការពារជាតិ នៅក្នុងក្របខ័ណ្ឌនៃកិច្ចដំណើរការរៀបចំថវិកាជាតិប្រចាំឆ្នាំ
- ធ្វើរបាយការណ៍អំពីលទ្ធផលនៃការជ្រើសរើសប្រជាពលរដ្ឋចូលបំពេញកាតព្វកិច្ចយោធាជូនប្រមុខរាជរដ្ឋាភិបាល
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីប្រមុខរាជរដ្ឋាភិបាល។

**មាត្រា២២ .-**

**គ.ក.យ.** មានសិទ្ធិបង្កើតគណៈកម្មការឬក្រុមការងារតាមការចាំបាច់។

**គ.ក.យ.** មានសិទ្ធិប្រើត្រារបស់ក្រសួងការពារជាតិ។

**មាត្រា២៣ .-**

គណៈកម្មាធិការកាតព្វកិច្ចយោធាកងទ័ពជើងគោកដូចមានចែងក្នុងមាត្រា២៤នៃអនុក្រឹត្យនេះ បំពេញមុខងារជាលេខាធិការដ្ឋានរបស់ **គ.ក.យ.**។

ការរៀបចំនិងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋានរបស់ **គ.ក.យ.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ក.យ.**។

## ផ្នែកទី២
## ការបង្កើតគណៈកម្មាធិការកាតព្វកិច្ចយោធាកងទ័ពជើងគោក

**មាត្រា២៤ .-**

ត្រូវបានបង្កើតគណៈកម្មាធិការកាតព្វកិច្ចយោធាកងទ័ពជើងគោក ដែលសរសេរជាអក្សរកាត់ថា **គ.ក.ជ.** មានសមាសភាពដូចតទៅ៖

| | |
|---|---|
| - មេបញ្ជាការកងទ័ពជើងគោក | ប្រធាន |
| - មេបញ្ជាការរងកងទ័ពជើងគោក ១រូប | អនុប្រធានអចិន្ត្រៃយ៍ |
| - មេបញ្ជាការរងកងទ័ពជើងអាកាស ១រូប | អនុប្រធាន |
| - មេបញ្ជាការរងកងទ័ពជើងទឹក ១រូប | អនុប្រធាន |
| - មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស ១រូប | អនុប្រធាន |
| - នាយរងសេនាធិការចម្រុះ អគ្គបញ្ជាការដ្ឋាន ១រូប | អនុប្រធាន |
| - មេបញ្ជាការយោធភូមិភាគ | អនុប្រធាន |
| - មេបញ្ជាការតំបន់ប្រតិបត្តិការសឹករង | សមាជិក |
| - មេបញ្ជាការកងរាជអាវុធហត្ថរាជធានី ខេត្ត | សមាជិក |
| - នាយករង ទីចាត់ការបុគ្គលិក អគ្គបញ្ជាការដ្ឋាន ១រូប | សមាជិក |
| - នាយករង ទីចាត់ការឃោសនាព័ត៌មាន អគ្គបញ្ជាការដ្ឋាន ១រូប | សមាជិក |
| - នាយករង នាយកដ្ឋានបុគ្គលិក ក្រសួងការពារជាតិ ១រូប | សមាជិក |
| - នាយការិយាល័យទី១ កងទ័ពជើងគោក | សមាជិក |
| - នាយការិយាល័យទី៤ កងទ័ពជើងគោក | សមាជិក |
| - នាយការិយាល័យទី៥ កងទ័ពជើងគោក | សមាជិក |
| - នាយការិយាល័យហិរញ្ញវត្ថុ កងទ័ពជើងគោក | សមាជិក |
| - នាយការិយាល័យសុខាភិបាល កងទ័ពជើងគោក | សមាជិក។ |

សមាសភាពជាក់ស្តែងនៃ **គ.ក.ជ.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ក.យ.**។

**គ.ក.ជ.** អាចមានសមាសភាពបន្ថែមតាមការចាំបាច់ ដែលត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ក.យ.**។

អនុប្រធាននិងសមាជិកនៃ **គ.ក.ជ.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន **គ.ក.ជ.**។ ក្នុងករណីចាំបាច់ ប្រធាន **គ.ក.ជ.** អាចប្រគល់សិទ្ធិជូនអនុប្រធានណាម្នាក់ ដើម្បីអញ្ជើញនិងដឹកនាំកិច្ចប្រជុំជំនួសបាន។

ប្រធាន **គ.ក.ជ.** មានសិទ្ធិអញ្ជើញសមាសភាពពាក់ព័ន្ធផ្សេងទៀតចូលរួមប្រជុំតាមការចាំបាច់។

**មាត្រា២៥ .–**

**គ.ក.ខ.** មានតួនាទីនិងភារកិច្ច ដូចតទៅ៖

- ដឹកនាំការធ្វើជំរឿនកាតព្វកិច្ចយោធា
- ដឹកនាំការជ្រើសរើសនិងពិនិត្យកាយសម្បទានិងសុខភាពប្រជាពលរដ្ឋដែលចូលបំពេញកាតព្វកិច្ចយោធា
- ដឹកនាំការធានាសុវត្ថិភាពដល់ដំណើរការជ្រើសរើសប្រជាពលរដ្ឋដែលចូលបំពេញកាតព្វកិច្ចយោធា
- ដឹកនាំការផ្សព្វផ្សាយតាមគ្រប់មធ្យោបាយអំពីច្បាប់ស្តីពីកាតព្វកិច្ចយោធាដល់ប្រជាពលរដ្ឋខ្មែរគ្រប់រូប
- រៀបចំផែនការសកម្មភាពរបស់ **គ.ក.ខ.**
- រៀបចំផែនការថវិការួមរបស់គណៈកម្មាធិការដែលមានចែងក្នុងជំពូកទី៦នៃអនុក្រឹត្យនេះ ដើម្បីដាក់ជូន **គ.ក.យ.** ពិនិត្យនិងសម្រេច
- បែងចែកសន្ទស្សន៍ក្នុងការជ្រើសរើសតាមភូមិសាស្ត្រ
- ទទួលពាក្យបណ្តឹងតវ៉ារបស់ប្រជាពលរដ្ឋដែលត្រូវបានអញ្ជើញឱ្យចូលបំពេញកាតព្វកិច្ចយោធា
- ធ្វើរបាយការណ៍ជាប្រចាំអំពីលទ្ធផលនៃដំណើរការការងាររបស់ខ្លួនជូន **គ.ក.យ.**
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីប្រធាន **គ.ក.យ.**។

**មាត្រា២៦ .–**

**គ.ក.ខ.** មានសិទ្ធិបង្កើតក្រុមការងារតាមការចាំបាច់។

**គ.ក.ខ.** មានសិទ្ធិប្រើត្រារបស់បញ្ជាការដ្ឋានកងទ័ពជើងគោក។

## ផ្នែកទី៣
## ការបង្កើតគណៈកម្មាធិការកាតព្វកិច្ចយោធាយោធភូមិភាគ

**មាត្រា២៧ .–**

ត្រូវបានបង្កើតគណៈកម្មាធិការកាតព្វកិច្ចយោធាយោធភូមិភាគ ដែលសរសេរជាអក្សរកាត់ថា **គ.ក.ភ.** មានសមាសភាពដូចតទៅ៖

| | |
|---|---|
| - មេបញ្ជាការយោធភូមិភាគ | ប្រធាន |
| - មេបញ្ជាការរងយោធភូមិភាគ ១រូប | អនុប្រធានអចិន្ត្រៃយ៍ |
| - មេបញ្ជាការតំបន់ប្រតិបត្តិការសឹករង | អនុប្រធាន |
| - មេបញ្ជាការកងរាជអាវុធហត្ថរាជធានី ខេត្ត | អនុប្រធាន |
| - នាយសេនាធិការរងយោធភូមិភាគ ១រូប | សមាជិក |
| - នាយការិយាល័យទី៤ យោធភូមិភាគ ១រូប | សមាជិក |
| - នាយការិយាល័យទី៥ យោធភូមិភាគ ១រូប | សមាជិក |
| - នាយការិយាល័យហិរញ្ញវត្ថុ យោធភូមិភាគ ១រូប | សមាជិក |
| - នាយការិយាល័យសុខាភិបាល យោធភូមិភាគ ១រូប | សមាជិក |
| - នាយការិយាល័យទី១ យោធភូមិភាគ ១រូប | លេខាធិការ។ |

សមាសភាពជាក់ស្តែងនៃ **គ.ក.ភ.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ក.យ.**។

**គ.ក.ភ.** អាចមានសមាសភាពបន្ថែមតាមការចាំបាច់ ដែលត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ក.យ.**។

អនុប្រធាននិងសមាជិកនៃ **គ.ក.ភ.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន **គ.ក.ភ.**។ ក្នុងករណីចាំបាច់ ប្រធាន **គ.ក.ភ.** អាចប្រគល់សិទ្ធិជូនអនុប្រធានណាម្នាក់ ដើម្បីអញ្ជើញនិងដឹកនាំកិច្ចប្រជុំជំនួសបាន។

ប្រធាន **គ.ក.ភ.** មានសិទ្ធិអញ្ជើញសមាសភាពពាក់ព័ន្ធផ្សេងទៀតចូលរួមប្រជុំតាមការចាំបាច់។

**មាត្រា២៨ ._**

**គ.ក.ភ.** មានតួនាទីនិងភារកិច្ច ដូចតទៅៈ

- ដឹកនាំការធ្វើជំរឿនកាតព្វកិច្ចយោធាក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន
- ដឹកនាំការជ្រើសរើសនិងពិនិត្យកាយសម្បទានិងសុខភាពប្រជាពលរដ្ឋដែលចូលបំពេញកាតព្វកិច្ចយោធា
- ដឹកនាំការធានាសុវត្ថិភាពដល់ដំណើរការជ្រើសរើសប្រជាពលរដ្ឋដែលចូលបំពេញកាតព្វកិច្ចយោធា
- រៀបចំផែនការសកម្មភាពរបស់ **គ.ក.ភ.**
- ធ្វើការផ្សព្វផ្សាយតាមគ្រប់មធ្យោបាយអំពីច្បាប់ស្តីពីកាតព្វកិច្ចយោធាដល់ប្រជាពលរដ្ឋខ្មែរគ្រប់រូប
- ធ្វើរបាយការណ៍ជាប្រចាំអំពីលទ្ធផលនៃដំណើរការការងាររបស់ខ្លួនជូន **គ.ក.ជ.**
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីប្រធាន **គ.ក.ជ.**។

**មាត្រា២៩ ._**

**គ.ក.ភ.** មានសិទ្ធិបង្កើតក្រុមការងារតាមការចាំបាច់។

**គ.ក.ភ.** មានសិទ្ធិប្រើត្រារបស់យោធភូមិភាគ។

## ផ្នែកទី៤
## ការបង្កើតគណៈកម្មាធិការកាតព្វកិច្ចយោធារាជធានី

**មាត្រា៣០ ._**

ត្រូវបានបង្កើតគណៈកម្មាធិការកាតព្វកិច្ចយោធារាជធានី ដែលសរសេរជាអក្សរកាត់ថា **គ.ក.រ.** មានសមាសភាពដូចតទៅៈ

| | |
|---|---|
| - មេបញ្ជាការកងរាជអាវុធហត្ថរាជធានីភ្នំពេញ | ប្រធាន |
| - មេបញ្ជាការរងកងរាជអាវុធហត្ថរាជធានីភ្នំពេញ ១រូប | អនុប្រធានអចិន្ត្រៃយ៍ |
| - នាយសេនាធិការរងកងទ័ពជើងគោក ១រូប | អនុប្រធាន |
| - នាយសេនាធិការរងយោធភូមិភាគពិសេស | អនុប្រធាន |
| - តំណាងរដ្ឋបាលរាជធានីភ្នំពេញ ១រូប | អនុប្រធាន |
| - នាយកាវិយាល័យទី១ យោធភូមិភាគពិសេស | សមាជិក |
| - នាយកាវិយាល័យទី៤ យោធភូមិភាគពិសេស | សមាជិក |
| - នាយកាវិយាល័យទី៥ យោធភូមិភាគពិសេស | សមាជិក |
| - នាយកាវិយាល័យហិរញ្ញវត្ថុ យោធភូមិភាគពិសេស | សមាជិក |
| - នាយកាវិយាល័យសុខាភិបាល យោធភូមិភាគពិសេស | សមាជិក |
| - មេបញ្ជាការមូលដ្ឋានកងរាជអាវុធហត្ថខណ្ឌ | សមាជិក |
| - នាយកាវិយាល័យផ្សព្វផ្សាយ កងរាជអាវុធហត្ថ | សមាជិក |
| - នាយកាវិយាល័យសុខាភិបាល កងរាជអាវុធហត្ថ | សមាជិក |
| - នាយកាវិយាល័យបុគ្គលិក កងរាជអាវុធហត្ថ | លេខាធិការ។ |

សមាសភាពជាក់ស្តែងនៃ **គ.ក.រ.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ក.យ.**។

**គ.ភ.រ.** អាចមានសមាសភាពបន្ថែមតាមការចាំបាច់ ដែលត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់ប្រធាន **គ.ភ.យ.**។

អនុប្រធាននិងសមាជិកនៃ **គ.ភ.រ.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន **គ.ភ.រ.**។ ក្នុងករណីចាំបាច់ ប្រធាន **គ.ភ.រ.** អាចប្រគល់សិទ្ធិជូនអនុប្រធានណាម្នាក់ ដើម្បីអញ្ជើញនិងដឹកនាំកិច្ចប្រជុំជំនួសបាន។

ប្រធាន **គ.ភ.រ.** មានសិទ្ធិអញ្ជើញសមាសភាពពាក់ព័ន្ធផ្សេងទៀតចូលរួមប្រជុំតាមការចាំបាច់។

**មាត្រា៣១ .-**

**គ.ភ.រ.** មានសិទ្ធិបង្កើតក្រុមការងារតាមតម្រូវការចាំបាច់។

**គ.ភ.រ.** មានសិទ្ធិប្រើត្រារបស់បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ។

## ផ្នែកទី៥
## ការបង្កើតគណៈកម្មាធិការកាតព្វកិច្ចយោធាខេត្ត

**មាត្រា៣២ .-**

ត្រូវបានបង្កើតគណៈកម្មាធិការកាតព្វកិច្ចយោធាខេត្ត ដែលសរសេរជាអក្សរកាត់ថា **គ.ភ.ខ.** មានសមាសភាពដូចតទៅ៖

| | |
|---|---|
| - មេបញ្ជាការតំបន់ប្រតិបត្តិការសឹករង | ប្រធាន |
| - មេបញ្ជាការកងរាជអាវុធហត្ថខេត្ត | អនុប្រធានអចិន្ត្រៃយ៍ |
| - មេបញ្ជាការរងតំបន់ប្រតិបត្តិការសឹករង ១រូប | អនុប្រធាន |
| - តំណាងរដ្ឋបាលខេត្ត ១រូប | អនុប្រធាន |
| - នាយការិយាល័យទី៤ តំបន់ប្រតិបត្តិការសឹករង | សមាជិក |
| - នាយការិយាល័យទី៥ តំបន់ប្រតិបត្តិការសឹករង | សមាជិក |
| - នាយការិយាល័យហិរញ្ញវត្ថុ តំបន់ប្រតិបត្តិការសឹករង | សមាជិក |
| - នាយការិយាល័យសុខាភិបាល តំបន់ប្រតិបត្តិការសឹករង | សមាជិក |
| - មេបញ្ជាការមូលដ្ឋានកងរាជអាវុធហត្ថក្រុង ស្រុក | សមាជិក |
| - នាយការិយាល័យបុគ្គលិក កងរាជអាវុធហត្ថខេត្ត | សមាជិក |
| - នាយការិយាល័យទី១ តំបន់ប្រតិបត្តិការសឹករង | លេខាធិការ។ |

សមាសភាពជាក់ស្ដែងនៃ **គ.ភ.ខ.** ត្រូវតែងតាំងដោយសេចក្ដីសម្រេចរបស់ប្រធាន **គ.ភ.យ.**។

**គ.ភ.ខ.** អាចមានសមាសភាពបន្ថែមតាមការចាំបាច់ ដែលត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់ប្រធាន **គ.ភ.យ.**។

អនុប្រធាននិងសមាជិកនៃ **គ.ភ.ខ.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន **គ.ភ.ខ.**។ ក្នុងករណីចាំបាច់ ប្រធាន **គ.ភ.ខ.** អាចប្រគល់សិទ្ធិជូនអនុប្រធានណាម្នាក់ ដើម្បីអញ្ជើញនិងដឹកនាំកិច្ចប្រជុំជំនួសបាន។

ប្រធាន **គ.ភ.ខ.** មានសិទ្ធិអញ្ជើញសមាសភាពពាក់ព័ន្ធផ្សេងទៀតចូលរួមប្រជុំតាមការចាំបាច់។

**មាត្រា៣៣ .-**

**គ.ភ.ខ.** មានសិទ្ធិបង្កើតក្រុមការងារតាមការចាំបាច់។

**គ.ភ.ខ.** មានសិទ្ធិប្រើត្រារបស់តំបន់ប្រតិបត្តិការសឹករង។

## ផ្នែកទី៦
## តួនាទីនិងភារកិច្ចរបស់គណៈកម្មាធិការកាតព្វកិច្ចយោធារាជធានី ខេត្ត

**មាត្រា៣៤ ._**

**គ.ក.រ.** និង **គ.ក.ខ.** មានតួនាទីនិងភារកិច្ច ដូចតទៅៈ

- ដឹកនាំការធ្វើជំរឿនកាតព្វកិច្ចយោធាក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន
- ដឹកនាំការធានាសុវត្ថិភាពដល់ដំណើរការជ្រើសរើសប្រជាពលរដ្ឋដែលចូលបំពេញកាតព្វកិច្ចយោធា
- រៀបចំផែនការសកម្មភាពរបស់ **គ.ក.រ.** និង **គ.ក.ខ.**
- ធ្វើការផ្សព្វផ្សាយតាមគ្រប់មធ្យោបាយអំពីច្បាប់ស្តីពីកាតព្វកិច្ចយោធាដល់ប្រជាពលរដ្ឋខ្មែរគ្រប់រូប
- ធ្វើរបាយការណ៍ជាប្រចាំអំពីលទ្ធផលនៃដំណើរការការងាររបស់ខ្លួនជូន **គ.ក.ភ.**
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីប្រធាន **គ.ក.ភ.**។

## ផ្នែកទី៧
## ការបង្កើតគណៈកម្មាធិការកាតព្វកិច្ចយោធាក្រុង ស្រុក ខណ្ឌ

**មាត្រា៣៥ ._**

ត្រូវបានបង្កើតគណៈកម្មាធិការកាតព្វកិច្ចយោធាក្រុង ស្រុក ខណ្ឌ ដែលសរសេរជាអក្សរកាត់ថា **គ.ក.ក.ស.ខ.** មានសមាសភាពដូចតទៅៈ

- មេបញ្ជាការមូលដ្ឋានកងរាជអាវុធហត្ថក្រុង ស្រុក ខណ្ឌ ប្រធាន
- មេបញ្ជាការរងមូលដ្ឋានកងរាជអាវុធហត្ថក្រុង ស្រុក ខណ្ឌ ១រូប អនុប្រធានអចិន្ត្រៃយ៍
- តំណាងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ១រូប អនុប្រធាន
- ជំនួយការបុគ្គលិកមូលដ្ឋានកងរាជអាវុធហត្ថ ១រូប លេខាធិការ
- នាយទាហាន នាយទាហានរង នៃកងរាជអាវុធហត្ថ សមាជិក។

សមាសភាពជាក់ស្តែងនៃ **គ.ក.ក.ស.ខ.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ក.យ.**។

**គ.ក.ក.ស.ខ.** អាចមានសមាសភាពបន្ថែមតាមការចាំបាច់ ដែលត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ក.យ.**។

អនុប្រធាននិងសមាជិកនៃ **គ.ក.ក.ស.ខ.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន **គ.ក.ក.ស.ខ.**។ ក្នុងករណីចាំបាច់ ប្រធាន **គ.ក.ក.ស.ខ.** អាចប្រគល់សិទ្ធិជូនអនុប្រធានណាម្នាក់ដើម្បីអញ្ជើញនិងដឹកនាំកិច្ចប្រជុំជំនួសបាន។

ប្រធាន **គ.ក.ក.ស.ខ.** មានសិទ្ធិអញ្ជើញសមាសភាពពាក់ព័ន្ធផ្សេងទៀតចូលរួមប្រជុំតាមការចាំបាច់។

**មាត្រា៣៦ ._**

**គ.ក.ក.ស.ខ.** មានតួនាទីនិងភារកិច្ច ដូចតទៅៈ

- ធ្វើការផ្សព្វផ្សាយតាមគ្រប់មធ្យោបាយអំពីច្បាប់ស្តីពីកាតព្វកិច្ចយោធាដល់ប្រជាពលរដ្ឋខ្មែរគ្រប់រូប
- ប្រមូលទិន្នន័យពីអាជ្ញាធរមូលដ្ឋាន ចំពោះប្រជាពលរដ្ឋដែលមានអាយុចាប់ពី ១៧ (ដប់ប្រាំពីរ) ឆ្នាំ ដល់ ២៥ (ម្ភៃប្រាំ) ឆ្នាំ
- រៀបចំបញ្ជីឈ្មោះប្រជាពលរដ្ឋដែលមានអាយុចាប់ពី ១៧ (ដប់ប្រាំពីរ) ឆ្នាំ ដល់ ២៥ (ម្ភៃប្រាំ) ឆ្នាំ ដែលស្ថិតក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន ជូនទៅ **គ.ក.រ.** និង **គ.ក.ខ.**

- បញ្ជូនលិខិតអញ្ជើញចូលបំពេញកាតព្វកិច្ចយោធាទៅសាមីជន ដោយសហការជាមួយអាជ្ញាធរមូលដ្ឋាន
- ទទួលពាក្យសុំស្ម័គ្រចិត្តចូលបំពេញកាតព្វកិច្ចយោធា
- ទទួលឯកសារសុំពន្យារពេលនិងរួចផុតពីកាតព្វកិច្ចយោធា ដើម្បីបញ្ជូនទៅ **គ.ក.ជ.** តាមឋានានុក្រម
- ធ្វើរបាយការណ៍ជាប្រចាំអំពីលទ្ធផលនៃដំណើរការការងាររបស់ខ្លួនជូន **គ.ក.រ.** និង **គ.ក.ខ.**
- អនុវត្តភារកិច្ចផ្សេងៗទៀត តាមការប្រគល់ពីប្រធាន **គ.ក.រ.** និង **គ.ក.ខ.**។

## ផ្នែកទី៨

## អ្នកឯកទេសជំនាញ

**មាត្រា៣៧ .-**

អ្នកឯកទេសជំនាញដែលបានចុះកិច្ចសហប្រតិបត្តិការបំពេញបេសកកម្មស្រាវជ្រាវឬអនុវត្តផ្ទាល់នូវកិច្ចការដែលជាប្រយោជន៍សាធារណៈនៃកងយោធពលខេមរភូមិន្ទ ដែលមានរយៈពេលស្មើនឹងស្ថានភាពកាតព្វកិច្ចយោធាចំនួន ២៤ (ម្ភៃបួន) ខែ ដើម្បីរួចផុតពីកាតព្វកិច្ចយោធា ត្រូវដាក់ពាក្យនៅ **គ.ក.ក.ស.ខ.** ឬ **គ.ក.ជ.**។

កិច្ចការនៃអ្នកឯកទេសជំនាញទាំងនោះរួមមានសេវា៖

- ផ្នែកវិស្វកម្ម ស្ពានថ្នល់ និងសំណង់
- ផ្នែកបោសសម្អាតមីននិងយុទ្ធភណ្ឌមិនទាន់ផ្ទុះ
- ផ្នែកសុខាភិបាល
- ផ្នែកទូរគមនាគមន៍
- ផ្នែកព័ត៌មានវិទ្យា។

## ផ្នែកទី៩

## ប្រភពធនធាន

**មាត្រា៣៨ .-**

ធនធានសម្រាប់ដំណើរការរបស់គណៈកម្មាធិការដែលមានចែងក្នុងជំពូកទី៦នៃអនុក្រឹត្យនេះ មានប្រភពមកពីថវិកាជាតិ ជាកញ្ចប់ថវិកាដោយឡែក នៅក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងការពារជាតិ។

# ជំពូកទី៧

# អន្តរប្បញ្ញត្តិ

**មាត្រា៣៩ .-**

លិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលពាក់ព័ន្ធនឹងការអនុវត្តអនុក្រឹត្យលេខ២០០ អនក្រ.បក ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីលក្ខខណ្ឌនិងបែបបទនៃការធ្វើជំរឿន ការជ្រើសរើស ការអញ្ជើញ ការពន្យារពេលសម្រាប់យុវជនកំពុងជាប់ការសិក្សា ប្រជាពលរដ្ឋដែលស្ថិតក្នុងករណីពិសេស និងការអនុវត្តច្បាប់ស្តីពីកាតព្វកិច្ចយោធា ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**មាត្រា៤០ .–**

អនុក្រឹត្យលេខ២០០ អនក្រ.បក ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីលក្ខខណ្ឌនិងបែបបទនៃការធ្វើជំរឿន ការជ្រើសរើស ការអញ្ជើញ ការពន្យារពេលសម្រាប់យុវជនកំពុងជាប់ការសិក្សា ប្រជាពលរដ្ឋដែលស្ថិតក្នុងករណីពិសេស និងការអនុវត្តច្បាប់ស្តីពីកាតព្វកិច្ចយោធា និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤១ .–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ១៤រោច ខែទុតិយាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ សីហា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ